## ២

ពេលវេលាកន្លងទៅយឺតៗនៅក្នុងលោករបស់មនុស្សពីរនាក់ ដែលមានមនោសញ្ចេតនាចំពោះគ្នាយ៉ាងជ្រាលជ្រៅ។ ក្មេងប្រុសឈប់រឹងទទឹងនឹងការមកមន្ទីរពេទ្យទៀត ផ្ទុយមកវិញគេបែរជាទទួលអារម្មណ៍ចូលចិត្តទីនេះកាន់តែខ្លាំង... ព្រោះមិត្តថ្មីដែលគួរឲ្យស្រលាញ់ប្រៀបដូចកូនតុក្កតាបានធ្វើឲ្យរឿងរ៉ាវល្អៗច្រើនយ៉ាងកើតឡើងបន្ថែមពេញបេះដូងរបស់គេ។ កុមារទាំងពីរប្រើពេលវេលានៅជាមួយគ្នាយូរសែនយូរ។ កុមារីចាប់ផ្ដើមមានសេចក្ដីសង្ឃឹមឡើងវិញ... យ៉ាងហោចណាស់នាងក៏ត្រូវថែរក្សាខ្យល់ដង្ហើមទុកសម្រាប់ថ្ងៃស្អែកនេះ ដើម្បីបានមកជួបក្មេងប្រុសនៅវាលស្មៅទៀត... នាងចាប់ផ្ដើមមានកម្លាំងចិត្តដើម្បីតស៊ូជាមួយនឹងជំងឺដ៏កាចសាហាវ ដែលកំពុងតាមយាយីយកខ្យល់ដកដង្ហើមរបស់នាងគ្រប់ពេលវេលា។ តែក្នុងពេលជាមួយគ្នានោះ... អារម្មណ៍មួយទៀតក៏ចាប់ផ្ដើមភ័យខ្លាចសេចក្ដីស្លាប់ឡើងមកភ្លាមៗជិតជាប់ក្នុងថ្លើមប្រមាត់របស់នាង។

បើត្រូវឃ្លាតទៅកាន់ពិភពលោកមួយទៀតដែលនៅឆ្ងាយសែនឆ្ងាយ... ក៏ប្រហែលជាលែងបានជួបគ្នាទៀតហើយ។

គ្រាន់តែគិត ក៏ឈឺចុកចាប់ពន់ពេកប្រមាណ...

រាងកាយតូចៗរបស់កុមារានិងកុមារី កំពុងអង្គុយបញ្ឈរជង្គង់មើលលំហមេឃដ៏ធំល្វឹងល្វើយ។ ពេលនេះ អ្នកជំងឺព្រមពាក់អាវដៃវែងចុះមកពីបន្ទប់ហើយ ព្រោះមិនត្រូវការឲ្យក្មេងប្រុសត្រូវមករងាដោយសារការលះបង់អាវមកដណ្ដប់ឲ្យខ្លួនឯងនោះទេ។

«បើចេញពីមន្ទីរពេទ្យរួចហើយ ខ្ញុំនឹងនាំនាងទៅលេងសមុទ្រ នាំទៅមើលភ្នំខ្ពស់ នាំទៅមើលផ្កានៅក្នុងសួនដែលស្អាតជាងនេះ នាំទៅ...»

«យើងប្រហែលជាគ្មានខ្យល់ដកដង្ហើមទៅដល់ថ្ងៃនោះទេ ហើយក៏ប្រហែលជាគ្មានថ្ងៃបានទៅទីនោះដែរ... ហេតុដូច្នេះឯងមិនបាច់និយាយទេ!»

កុមារីប្រឹងរម្ងាប់អារម្មណ៍បញ្ជាក់ប្រាប់គេដោយសំឡេងខ្សោះខ្សោយ។ គ្រាន់តែធ្វើអ្វីប្រឆាំងនឹងចង្វាក់បេះដូងបន្តិច នាងនឿយហត់ស្ទើរតែដកដង្ហើមមិនដល់គ្នាទៅហើយ គ្មានថ្ងៃដែលនឹងអាចទៅដល់ទីកន្លែងទាំងអស់នោះបានទេ... ទាំងភាពទន់ខ្សោយទាំងជំងឺកាចសាហាវ ពិតជាគ្មានផ្លូវបើកឱកាសឲ្យនាងយ៉ាងប្រាកដ។

«ខ្ញុំជឿជាក់ថានាងនឹងបានជាសះស្បើយ... ហើយថ្ងៃណាមួយយើងនឹងទៅទីកន្លែងទាំងនោះជាមួយគ្នា!» ក្មេងប្រុសពោលឡើងយ៉ាងប្រាកដប្រជា។

«ឯងនឹងមិនបោះបង់យើងចោល ដូចប៉ាម៉ាក់ដែលទុកយើងចោលនៅទីនេះទេឬ?»

«បើនៅមានខ្យល់ដកដង្ហើម ខ្ញុំគ្មានថ្ងៃបណ្ដោយឲ្យនាងនៅកណ្ដោចកណ្ដែង និងគ្មានថ្ងៃបោះបង់ចោលនាងនោះទេ!»

«បើយើងត្រូវស្លាប់... តើអាចសុំឲ្យយើងអស់ខ្យល់ដកដង្ហើមនៅក្បែរៗឯងបានឬទេ? បើយើងត្រូវឃ្លាតទៅនៅពិភពលោកមួយដែលកណ្ដោចកណ្ដែង សូមឲ្យយើងចងចាំឯងទុកជាការចងចាំចុងក្រោយ។» នាងឈ្ងោកមុខចុះនៅពេលនិយាយចប់ប្រយោគ។

គេប្រហែលជាមិនដឹងទេ ថានាងវេទនាប៉ុណ្ណាដែលត្រូវមានជីវិតរស់នៅរាល់ថ្ងៃនេះ។ យប់ខ្លះដែលសុបិនអាក្រក់ ភ្ញាក់ឡើងកណ្ដាលអធ្រាត្រ មិនឃើញនរណាម្នាក់សោះ។ ប៉ាម៉ាក់នៅឯផ្ទះជាមួយប្អូនប្រុសតែម្នាក់របស់នាង។ លោកទាំងពីរជួលគិលានុបដ្ឋាយិកាពិសេស ដើម្បីមកមើលថែរក្សានាង។ គ្រប់យ៉ាងល្អទាំងអស់ តែវានឹងមានប្រយោជន៍អ្វីទៅ ព្រោះអ្វីដែលនាងត្រូវការមិនមែនអត្ថន័យដែលលុយអាចរកទិញមកបាននោះទេ គឺត្រឹមតែសេចក្ដីស្រលាញ់... ត្រឹមតែការលួងលោមពីអ្នកដែលបង្កើតខ្លួនមកប៉ុណ្ណោះឯង។ នាងកើតមកដើម្បីបង្កការលំបាកឲ្យគ្រួសារ... រូបភាពដែលនាងឃើញប៉ាម៉ាក់សម្ដែងសេចក្ដីស្រលាញ់ និងយកចិត្តចំពោះប្អូនប្រុស ធ្វើឲ្យនាងទទួលអារម្មណ៍ថា ខ្លួនឯងជាមនុស្សកាកសំណល់។ តាមពិតទៅ នាងមិនគួរនឹងកើតមកសោះ!

ពិភពលោករបស់នាងក្នុងនាទីនេះ គឺមានតែគេប៉ុណ្ណោះ គឺតែម្នាក់ពិតមែនដែលធ្វើឲ្យទទួលអារម្មណ៍ថានាងមិនមែនមានតែខ្លួនមួយ។ បើត្រូវស្លាប់ក្នុងថ្ងៃខាងមុខណាមួយ... ក៏ប្រហែលជាល្អបើបានស្លាប់នៅក្បែរៗគេ។ យ៉ាងហោចណាស់... ខ្យល់ដង្ហើមចុងក្រោយនឹងបានចងចាំរូបរបស់គេទុកដើម្បីជួយលួងលោមខ្លួនឯង ពេលចាកចេញទៅហើយ ឆ្ងាយសែនឆ្ងាយ។

«ឈប់និយាយរឿងសេចក្តីស្លាប់ទៀតទៅ... ខ្ញុំគ្មានថ្ងៃព្រមបណ្តោយឲ្យនាង កើតក្តីអន្តរាយឡើយ...» ក្មេងប្រុសបន្ទោសសំឡេងមាំ តែពេលឃើញកែវភ្នែកមូលក្រឡង់នោះ ដោរជន់ដោយទឹកភ្នែកក៏បន្ទាបសំឡេងចុះវិញ។ ដៃតូចលូកទៅចាប់ដៃផ្ការាងអង្អែលតិចៗ ដើម្បីផ្តល់ភាពកក់ក្តៅនិងកម្លាំងចិត្ត។

«សុំទោសដែលខ្ញុំឆេវឆាវបន្តិច ព្រោះទទួលអារម្មណ៍ឈឺចុកចាប់ពេក នៅពេលគិតថាថ្ងៃស្អែកនេះ... គ្មាននាងនៅក្បែរ។»

«មិនប៉ុន្មានថ្ងៃទៀត លោកយាយរបស់ឯងនឹងត្រលប់ទៅផ្ទះវិញហើយ... ហើយក៏ប្រហែលជាលែងបានមកលេងយើងទៀតដែរមែនទេ... តើឯងនឹងត្រលប់មករកយើងវិញទេ?» កុមារីផ្តោតភ្នែកសម្លឹងមើលគេ។ នៅក្នុងក្រសែភ្នែកនោះរំជើបរំជួលនឹងចម្លើយតបយ៉ាងខ្លាំង។

«ប្រាកដណាស់... វាត្រូវតែដូច្នោះស្រាប់ហើយ សុំសន្យាដាក់ជីវិត!»

កុមារាហុចម្រាមកូនដៃជំនួសឲ្យពាក្យសន្យា។ បន្តិចមក ស្រីតូចក៏ប្រើកូនដៃរបស់ខ្លួនឯងផ្តក់ជាប់... ទទួលយកពាក្យសន្យានោះ។

«ចាំទុកណា បើនៅមានខ្យល់ដកដង្ហើម ខ្ញុំនឹងគ្មានថ្ងៃបោះបង់ចោលនាងជាដាច់ខាត... ដោយជីវិតរបស់មនុស្សម្នាក់... សន្យាថានឹងចាំមើលថែរក្សាការពារនាងរហូតទៅ!»

* * *

មិនប៉ុន្មានថ្ងៃក្រោយមក ប្រុសតូចប្រញាប់រត់ចុះមកពីបន្ទប់សម្រាករបស់លោកយាយនៅពេលកុមារីទូរស័ព្ទទៅប្រាប់ថា នាងកំពុងត្រៀមខ្លួនត្រលប់ទៅផ្ទះឯបាត់ដំបងវិញហើយ។ គេរត់បុកអ្នកនេះអ្នកនោះតាមផ្លូវរហូត ទាំងនឹកខឹងនិងតូចចិត្តដែលនៅសុខៗក៏ឃ្លាតទៅ ធ្វើដូចជាគេនោះគ្មានតម្លៃអ្វីសោះឡើយ។

រាងតូចស្តើងឈរនៅកណ្តាលវាលស្មៅពណ៌បៃតងខ្ចី នាងងាកត្រលប់មកមើលមិត្តដែលទើបមកដល់យឺតៗ។ រស្មីស្រទន់របស់ព្រះអាទិត្យដែលចាំងចុះមក ធ្វើឲ្យស្នាមញញឹមនៅលើផ្ទៃមុខស្រស់ផូរផង់នោះសោកសៅគួរឲ្យចង់ខឹង។

«គិតថាខ្លួននេះជានរណា គិតចង់ទៅក៏ទៅដោយងាយៗយ៉ាងនេះឬ?»

ពាក្យដំបូងផ្ទុះចេញមកដោយសំឡេងគ្រោតគ្រាត។

«សុំទោសផងដែលមិនបានប្រាប់ជាមុន រឿងវាទាន់ហន់ពេក ព្រោះលោកអ៊ំពេទ្យត្រលប់មកពីបរទេសលឿនជាងថ្ងៃកំណត់មុនមួយអាទិត្យ ទើបយើងត្រូវប្រញាប់ត្រលប់ទៅបាត់ដំបងវិញ។»

តាមពិតនាងខ្លួនឯងដែលជាអ្នករំអុកចង់ត្រលប់ទៅផ្ទះ ព្រោះមួយរយៈនេះបេះដូងរបស់នាងចុះខ្សោយជាលំដាប់ ឯសុបិនអាក្រក់ក៏មកលងបន្លាចឥតឈប់ឈរ ខ្លួនប្រាណប្រែជាត្រជាក់ស្រេបដូចមនុស្សជិតស្លាប់ ខ្លាចក្រែងថានៅទីនេះតទៅទៀត ក្មេងប្រុសអាចនឹងឃើញគេស្លាប់នៅចំពោះមុខ គេប្រហែលជាទទួលយកការឈឺចាប់នេះមិនបានទេ ហេតុដូច្នោះទើបត្រូវប្រញាប់ចាកចេញទៅមុន បើត្រូវស្លាប់គេក៏មិនគួរដឹងឮដែរ ចង់ឲ្យពិភពលោករបស់គេនោះមានរូបនាងជារៀងរហូត មិនចង់ឲ្យក្មេងប្រុសដឹងថានាងមិនបាននៅលើលោកនេះតទៅទៀតទេ។

«ខ្ញុំមិនចង់ឲ្យនាងឃ្លាតទៅសោះ... បាត់ដំបងឆ្ងាយណាស់សម្រាប់ឲ្យក្មេងៗធ្វើដំណើរទៅដល់បាន!»

«នេះជាបេះដូងរបស់យើង ឯងជួយមើលថែរក្សាផងណ៎ា!»

ស្រីតូចហុចប្រអប់តន្ត្រីបួនជ្រុង ដែលធ្វើអំពីឈើឆ្លាក់ជាក្បាច់រចនាយ៉ាងប្រណីត ឲ្យទៅមិត្តតែម្នាក់ដែលកំពុងមាន មុននឹងប្រាប់គេពីអត្ថន័យរបស់វា។

«នេះជារបស់ដែលយើងស្រលាញ់បំផុត! ប្រអប់តន្ត្រីនេះធ្វើឲ្យបេះដូងយើងលោតបានដោយមិនបាច់ឈប់ធ្វើការ។ នៅពេលឈឺធ្ងន់ម្ដងៗ លុះបានឮសំឡេងភ្លេងនេះ យើងនឹងមានកម្លាំងកំហែងបើកភ្នែកឡើងមកតស៊ូជាមួយនឹងភាពឈឺចុកចាប់តទៅទៀតបាន។»

«បើដូច្នោះគួរតែរក្សាទុកដោយខ្លួនឯង... ព្រោះវាមានន័យសំខាន់ខ្លាំងណាស់!»

គេមិនហ៊ានទទួលទុក ខ្លាចថាបើនាងឈឺនឹងមិនអាចស្ដាប់ភ្លេងចេញពីវាបានទៀត ហើយនឹងក្លាយជាទន់ខ្សោយគ្មានកម្លាំងចិត្តដើម្បីតស៊ូនឹងជំងឺកាចសាហាវ។

«របស់សំខាន់ក៏ត្រូវតែរក្សាទុកនៅជាមួយមនុស្សសំខាន់! ចាប់តាំងពីពេលនេះតទៅសូមជួយមើលថែរក្សាបេះដូងយើងផង។»

«អ្នកនាងតូចលោកប៉ាអ្នកម៉ាក់ឲ្យមកតាម ព្រោះត្រូវប្រញាប់ចេញទៅពីព្រឹកផង!»គិលានុបដ្ឋាយិកាពិសេសស្រែកហៅមកពីចម្ងាយ ព្រោះដល់ពេលវេលាដែលត្រូវចេញដំណើរហើយ។

«យើងត្រូវទៅហើយ... និយាយអ៊ីចឹង ឯងឈ្មោះអ...»

«ចាំមួយភ្លែត... មិនដល់ប៉ុន្មានវិនាទីទេ!»

ក្មេងប្រុសមិនបានឮសំណួរនោះ អ្វីដែលគេបានឮគឺសំឡេងបេះដូងរបស់ខ្លួនឯង។ ប្រុសតូចងាកមើលជុំវិញខ្លួន មុននឹងបញ្ឈប់ខ្សែភ្នែកត្រង់កំលោះក្រមុំមួយគូ ភាគីស្រីនោះជាអ្នកជំងឺ នាងអង្គុយនៅលើរទេះរុញ នៅក្នុងដៃមានផ្កាពណ៌សមួយបាច់ធំ ឯភាគីបុរសនៅឈរមើលថៃក្បែរកាយដោយក្ដីព្រួយបារម្ភ។ នៅពេលឃើញដូចនោះ ក្មេងប្រុសក៏ប្រឹងរត់អស់កម្លាំងជើងទៅកាន់គូស្នេហ៍នោះភ្លាមមុននឹងពោលចេញមកដោយសំឡេងប្រាកដប្រជា។

«បងស្រី! មិត្តរបស់ខ្ញុំកំពុងត្រលប់ទៅផ្ទះដែលនៅឆ្ងាយពីទីនេះខ្លាំងណាស់ ហើយមិនដឹងថានៅពេលណាយើងនឹងបានជួបគ្នាវិញទេ នាងឲ្យរបស់នេះជាកាដូសម្រាប់ខ្ញុំ» ក្មេងប្រុសហុចប្រអប់តន្ត្រីឈើឲ្យនារីលើរទេះរុញដែលកំពុងសម្លឹងមើលយ៉ាងចម្លែកចិត្ត «តែខ្ញុំបែរជាគ្មានអ្វីឲ្យនាងសោះ អឺ... តើខ្ញុំអាចសុំផ្កាមួយទងពីរបានឬទេ? ផ្កានេះប្រហែលជាមានអត្ថន័យ សម្រាប់ពួកបងៗទាំងពីរខ្លាំងណាស់... ហើយក៏ប្រហែលជាមានន័យសំខាន់សម្រាប់ពួកខ្ញុំដូចគ្នា!»

«បានតើប្រុសតូច!» នាងញញឹមចេញមកយ៉ាងអាណិតស្រលាញ់មុននឹងទាញយកផ្កាកុលាបសដែលរៀបចំជាបាច់យ៉ាងស្រស់ស្អាតហុចឲ្យមួយទង។

«បើសន្យាអ្វីហើយ... កុំភ្លេចធ្វើតាមសន្យាផងណា!» ជាសម្ដីរបស់បុរសម្ចាស់បាច់ផ្កាដ៏ស្រស់ស្អាតនោះឯង។ ជារឿងធម្មតាសម្រាប់មនុស្សដែលត្រូវបែកគ្នា តែងចូលចិត្តនិយាយពាក្យសន្យា ឯក្មេងប្រុសម្នាក់នេះក៏ប្រហែលជាមិនខុសគ្នាដែរ។

«បាទ! ខ្ញុំសូមឲ្យបងៗទាំងពីរស្រលាញ់គ្នារហូតទៅ អរគុណពួកបងខ្លាំងណាស់!» នៅពេលបានផ្កាហើយទើបប្រញាប់រត់ត្រលប់មកវិញជាបន្ទាន់។

«នេះក៏ជាបេះដូងរបស់ខ្ញុំដូចគ្នា!» គេហុចផ្កាឲ្យក្មេងស្រី។

«យើងនឹងរក្សាវាទុករហូតតទៅ!»

«នាងត្រូវថែរក្សាខ្លួនឯងឲ្យបានល្អ! នៅពេលធំឡើងខ្ញុំនឹងតាមរកនាងដោយខ្លួនឯង នាំមកនៅជាមួយគ្នានៅផ្ទះរបស់ពួកយើង នឹងមិនបណ្តោយឲ្យនាងយល់សប្តិអាក្រក់ ឬឃំយ៉ាងកណ្តោចកណ្តែងតទៅទៀតទេ។»

កែវភ្នែកពណ៌ត្នោតចាស់របស់ក្មេងប្រុស មើលទៅរឹងប៉ឹងម៉ឺងម៉ាត់ដូចភ្នំព្រះសុមេរុ។ គេក្តាប់ប្រអប់តន្ត្រីជាប់យ៉ាងហួងហែងព្រោះវាជាបេះដូងរបស់កុមារី។

«យើងនឹងរង់ចាំ... ចាំរហូតដល់ថ្ងៃចុងក្រោយ!»

ស្រីតូចសម្លឹងគេយ៉ាងអាលោះអាល័យ។ ខ្យល់ត្រជាក់ផាត់មក... ធ្វើឲ្យទទួលអារម្មណ៍ស្រងេះស្រងោចកប់យ៉ាងជ្រៅនៅក្នុងចិត្ត។

កែវភ្នែករបស់ពួកគេទាំងពីរ ឆ្លើយឆ្លងរកគ្នាយ៉ាងយូរសែនយូរ... ជាពាក្យសន្យាដែលទទួលដឹងឮទាំងអស់គ្នាដោយបេះដូងទាំងគូ។

* * *

*សូមរង់ចាំអានវគ្គ៣!*